**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**
**នាយកដ្ឋានកិច្ចការអាស៊ាន**
លេខ: ០៥/២០២២

ថ្ងៃអង្គារ ១០ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យសហប្រតិបត្តិការយោធាអន្តរជាតិ ស្នងការយោធាមជ្ឈិម នៃសាធារណៈរដ្ឋប្រជាមានិតចិន នឹងរៀបចំកិច្ចសន្ទនាមន្ត្រីការពារជាតិវេទិកាតំបន់អាស៊ាន (ARF DOD) ដែលនឹងប្រព្រឹត្តិទៅ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។

នៅក្នុងកិច្ចសន្ទនានោះមានការផ្តល់សន្ទរកថាគន្លឹះដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេស សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រោមមូលបទ "សាមគ្គីដើម្បីសន្តិសុខប្រកបដោយសុខដុម"។

សហប្រធានដឹកនាំកិច្ចសន្ទនាដោយ **ឧត្តមសេនីយ៍ឯក ឡៃ ចិន្តា** អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស និងជានាយក នាយកដ្ឋានកិច្ចការអាស៊ាន និង**ឧត្តមសេនីយ៍ទោ ហ្សាង បាវគួន** (Zhang Baoqun) អនុប្រធាន ការិយាល័យសហប្រតិបត្តិការយោធាអន្តរជាតិ ស្នងការយោធាមជ្ឈិម នៃសាធារណៈរដ្ឋប្រជាមានិតចិន។

កិច្ចសន្ទនាមន្ត្រីការពារជាតិវេទិកាតំបន់អាស៊ាន នឹងមានការចូលរួមពីបណ្តាប្រទេសសមាជិកអាស៊ានទាំង១០ និងប្រទេសក្រៅអាស៊ានដែលជាសមាជិកវេទិកាតំបន់អាស៊ាន និងដៃគូអាស៊ាន ដូចជា អូស្ត្រាលី បង់ក្លាដេស កាណាដា ចិន ឥណ្ឌា ជប៉ុន នូវែលហ្សេឡង់ សាធារណរដ្ឋកូរ៉េ រុស្ស៊ី សាធារណរដ្ឋ-ប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ម៉ុងហ្គោលី ប៉ាគីស្ថាន ប៉ាពួញូហ្គីនេ ស្រីលង្កា ទីម័រខាងកើត សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលនឹងពិភាក្សាលើប្រធានបទចំនួន៣ ដូចជា៖

**១.តួនាទីស្ថាប័នការពារជាតិក្នុងការគាំទ្រការស្តារឡើងវិញបន្ទាប់ពីកូវីដ១៩**

**២.ពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងការពារជាតិក្រោយវិបត្តិកូវីដ១៩**

**៣.ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការការពារជាតិក្នុងតំបន់**

**នាយកដ្ឋានកិច្ចការអាស៊ាន**